អត្ថបទល្ខោនបាសាក់

# រឿងតេជោយ៉ត

និពន្ធដោយ

លោក ទី ជិន្នុត

ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៨៣

អត្ថបទល្ខោនបាសាក់

# រឿងតេជោយ៉ត


អ្នកនិពន្ធ

លោក ទី ជីហួត

អ្នករៀបរៀង

អ្នកស្រី ប៊ី គីមសែន



បោះពុម្ពដោយ

លោក ស្រី ប៊ុនជន

បោះពុម្ពលើកទី២

ឆ្នាំ ២០០៤

# ឧទ្ទិសកថា

យើងខ្ញុំសូមសម្តែងនូវគារវៈ និងសរសើរអស់ពីដួងចិត្ត ចំពោះលោក ទី ជីហ្វួត កវីនិពន្ធខ្មែរដ៏ល្បីល្បាញ ក្នុងទំព័រប្រវត្តិអ្នកនិពន្ធខ្មែរ នាសម័យទំនើប ដែលលោកបានបូជាកម្លាំងកាយ ចិត្ត គំនិតប្រាជ្ញានិងសេចក្តីសុខដើម្បីស្តារឡើងវិញនូវវិស័យសិល្បៈល្ខោនបាសាក់ឱ្យរស់រានមានជីវិត ក្រោយពីរបបប៉ុល-ពតដួលរលំទៅ ។

សូមមហាពលិកម្មរបស់លោក ក្លាយជានិមិត្តរូបដ៏សក្តិសិទ្ធសំរាប់យុវជនខ្មែរគ្រប់ជំនាន់ ឱ្យចេះយកចិត្តទុកដាក់ និងជួយថែរក្សាព្រលឹងវប្បធម៌ អរិយធម៌ខ្មែរ ឱ្យរស់រានមានជីវិត និងមានភាពរីកចំរើននៅលើឆាកអន្តរជាតិ ។

សូមព្រលឹងវិញ្ញាណ ភ្លឺថ្លាប្រាជ្ញាមុតនៃទេពកោសល្យដ៏ល្បីល្បាញរបស់លោកសណ្ឋិតជិតជាប់ ក្នុងដួងចិត្តអ្នកស្នេហាការតែងនិពន្ធគ្រប់ៗគ្នា ដើម្បីបន្តវេនការច្នៃប្រឌិតវិស័យសិល្បៈល្ខោនបាសាក់ តរៀងទៅ ។

សូមឱ្យដួងវិញ្ញាណរបស់លោក ទី ជីហ្វួត អញ្ជើញទៅកាន់ទីឋានបរមសុខកុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

សូស្តីប្រិយមិត្តអ្នកអាន អ្នកសិក្សា ជាទីមេត្រី ! សៀវភៅដែលលោក-អ្នក និងប្អូនៗ នឹងត្រូវអាននាពេលនេះ ជាប្រភេទល្ខោនបាសាក់លំនាំប្រវត្តិសាស្ត្រ និងជាស្នាដៃនិពន្ធរបស់លោក **ឌី ខឹម្ហួត** (១៩៥២-១៩៨៧) នាក្រោយឆ្នាំ១៩៧៩ ។ នៅឆ្នាំ ២០០១ ក្រុមនិពន្ធសៀវភៅសិក្សានៃក្រសួងអប់រំយុវជន និងកីឡាបានដកស្រង់វគ្គខ្លះមកបញ្ចូលក្នុងកម្មវិធីសិក្សា ភាសាខ្មែរ ថ្នាក់ទី ១២ ជំពូក ៣ មេរៀន ទី៨ អំនានទី១ ។ ទោះបីយ៉ាងនេះ ក៏ដោយរឿង **តេជោយ៉ត** ពុំបានត្រូវគេចងក្រងជាឯកសារសៀវភៅទេ តែមានឯកសារជាកាសែ្សត (ម៉ាញ៉េ) ដែលត្រូវបានគ្រូបង្រៀនភាសាខ្មែរ ថ្នាក់ទី ១២ ខ្លះជាវកាសែ្សត (ម៉ាញ៉េ) តៗគ្នាមកចាក់ផ្សាយអោយសិស្សស្តាប់ នៅពេលដែលបង្រៀនដល់មេរៀននេះ ។ នៅឆ្នាំ ២០០២ នេះគេបានឃើញឯកសារមួយជាសៀវភៅរឿង **តេជោយ៉ត** ចម្លងចេញពីកាសែ្សត (ម៉ាញ៉េ) ដែលគេដឹងថា ជាការរៀប-រៀងរបស់សាស្ត្រាចារ្យ **នុត ធរតន្ថិ** បង្រៀនភាសាខ្មែរ ថ្នាក់ទី ១២ នៅវិទ្យាល័យនេត យ៉ង់ បាត់ដំបង តែសៀវភៅនោះមានឆាកខ្លះបាត់សេចក្តីសន្ទនា ហើយពុំមានឃ្លាចម្រៀងរបស់តួអង្គទេ ។ បច្ចុប្បន្នដោយយល់ឃើញថា ស្នាដៃនេះ មានអត្ថប្រយោជន៍ចំពោះអ្នកសិក្សា

អ្នកស្រាវជ្រាវ និងអ្នកអានទូទៅ ខ្ញុំក៏បានរៀបរៀងសរសេរបំពេញកន្លែងខ្វះចន្លោះ ទៅលើឯកសារដើមដែលមានស្រាប់ និងរៀបបញ្ចូលប្រវត្តិសង្ខេប និងស្នាដៃរបស់អ្នកនិពន្ធរូបនេះបន្ថែមទៀត ។

ខ្ញុំមានជំនឿថា សៀវភៅនេះនឹងជួយឱ្យអ្នកអានអ្នកសិក្សាមើលឃើញពីតំលៃល្ខោនបាសាក់ ដែលមានការអភិវឌ្ឍខាងផ្នែកស្មារតីការទទួលខុសត្រូវ ជាពិសេសការអប់រំឱ្យមានសេចក្ដីក្លាហាន ដើម្បីភាពយុត្តិធម៌ ដើម្បីប្រទេសជាតិ ប្រជារាស្ត្រ និងកាត់បន្ថយអំពើពុករលួយបក្សពួកនិយមនៅក្នុងសង្គមខ្មែរផងដែរ ។

ខ្ញុំសូមទទួលរាល់ការរិះគន់គ្រប់យ៉ាងដើម្បីការរីកចំរើន ។

សូមអរគុណ

ភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៤

# មាតិកា

| ល.រ | ចំណងជើង | ទំព័រ |
|---|---|---|
| ១ | ជីវប្រវត្តិសង្ខេបរបស់អ្នកនិពន្ធ.............................. | ១ |
| ២ | ប្រភេទស្នាដៃរបស់អ្នកនិពន្ធតាមឆ្នាំ (១៩៧៩-១៩៨៧).... | ៣ |
| ៣ | ឈ្មោះស្នាដៃមុនឆ្នាំ ១៩៧៥.............................. | ៤ |
| ៤ | ឈ្មោះស្នាដៃមួយចំនួនក្រោយឆ្នាំ ១៩៧៩.................... | ៤ |
| ៥ | សេចក្ដីផ្ដើម.............................................. | ៧ |
| ៦ | សង្ខេបរឿង.............................................. | ៩ |
| ៧ | តួអង្គនិងមុខងារ.......................................... | ១២ |
| ៨ | កាល និងទីកន្លែងនៃរឿង.................................. | ១៣ |
| ៩ | តម្រាក្បួនព្យូហ៍សឹកទាំង ១២.............................. | ១៣ |
| ១០ | រឿងតេជោយ៉ត............................................. | ១៦ |

# ជីវប្រវត្តិសង្ខេប

## អ្នកនិពន្ធល្ខោនបាសាក់ រឿងតេជោយ៉ត[១]

### I- ប្រវត្តិសង្ខេប

- ឈ្មោះ អ្នកនិពន្ធ : លោក ធី ជីហួត
- ថ្ងៃខែឆ្នាំកំណើត : ១០ ខែ កុម្ភៈ ឆ្នាំ ១៩៥២
- ស្រុកកំណើត : ភូមិត្រពាំងស្លា ឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ[២]
- កំរិតវប្បធម៌ : ថ្នាក់ទី៣ទំនើបជាតិ សាលាអនុវត្ត[៣] (មុនឆ្នាំ ១៩៧៥)
- កំរិតភាសាបរទេស : អាន និងសរសេរភាសាបារាំង
- ទទួលមរណភាព : ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៨៧ ដោយជម្ងឺក្រិនថ្លើម នៅរាជធានីភ្នំពេញ ។

---

(១) តាមឯកសារស្រាវជ្រាវរបស់និសិ្សត មហាវិទ្យាល័យអក្សរសាស្ត្រជំនាន់ទី ៩ (១៩៨៨-៩២) នៃសកលវិទ្យាល័យភ្នំពេញ ។

(២) ទីកន្លែងកំនើតឋូរថ្មី ដើម្បីបានចូលធ្វើការនៅភ្នំពេញ គឺកើតនៅសង្កាត់លេខ ៥ ក្រុង ភ្នំពេញ (ឯកសារខ្លះសង្កាត់លេខ ៤)

(៣) បច្ចុប្បន្នវិទ្យាល័យអនុវត្ត (ស្ថិតក្នុងបរិវេណមហាវិទ្យាល័យគរុកោសល្យ) ។

## II - អំពីប្រវត្តិការងារ

### ក. មុនឆ្នាំ ១៩៧៥

- ជាងកាត់សក់ ជិតផ្សារអូរឬស្សី នៅភ្នំពេញ ។

- ជាសិស្សសាលារៀនផង ដើរលក់នំបុំាង, លក់ប៉ោង៧, បំរើតុតាមហាង....... ដើម្បីចិញ្ចឹមក្រុមគ្រួសារ ក្នុងនាមខ្លួនជាកូនច្បង ។

- គេចាប់ធ្វើទាហាន ។

### ខ. ក្រោយឆ្នាំ ១៩៧៥

- ជន្លៀសទៅស្រុកខាងម្តាយ នៅភូមិកោះតូច ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល បាន៦ខែ ។

- ខ្មែរក្រហមបញ្ជូនទាំងគ្រួសារ ឱ្យទៅនៅភូមិត្រពាំងថ្ម សង្កាត់ប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបាត់ដំបង មានការងារជាអ្នកលាយជីលេខមួយគឺជីលាមកមនុស្ស ។

### គ. ក្រោយឆ្នាំ ១៩៧៩

- បានមកនៅខេត្តសៀមរាប ពីរខែ

- បន្តដំណើរទៅរស់នៅស្រុកកំណើតខាងម្តាយជាថ្មីទៀត ។

ក្រោយមកលោកបានមករស់នៅភ្នំពេញ ហើយចូលបំរើការនៅវិទ្យុជាតិកម្ពុជា ។

## III- អំពីស្នាដៃ

- ឆ្នាំ១៩៦៨ បានសរសេរកំណាព្យ មួយឈ្មោះថា "ក្តីលំបាក

វេទនារបស់កូនអ្នកក្រ និងការបែងចែកវណ្ណៈក្នុងសង្គមមនុស្ស "។

- ឆ្នាំ ១៩៧០ សរសេររឿង អ្នកលេងជាយសមុទ្រជាប្រភេទប្រលោមលោកដោយបោះលក់តាមទីផ្សារ ។

- ឆ្នាំ១៩៧២ សរសេររឿង គុហារថ្មលឿងជាប្រភេទប្រលោមលោកភាគ (៥ភាគ) បានធ្វើឱ្យគាត់ល្បីឈ្មោះ ។

- ឆ្នាំ ១៩៧២ បានចូលជាសមាជិកក្រុមអ្នកនិពន្ធខ្មែរ ។

ដូច្នេះនៅមុនឆ្នាំ ១៩៧៥ សរសេរ ប្រលោមលោក បាន ៨ ស្នាដៃ ។

- ក្រោយឆ្នាំ ១៩៧៩ គាត់សរសេរបាន ១៧៦ ស្នាដៃ ដែលក្នុងនោះមានអត្ថបទ ជាល្ខោនបាសាក់ ល្ខោនយីកេ ប្រលោមលោក ចម្រៀងអាយ៉ៃ......ជាដើម ។

- ស្នាដៃចុងក្រោយរបស់លោកគឺរឿងក្បួនជីវិត (២៨.០៣.១៩៨៧)

**ប្រភេទស្នាដៃតាមឆ្នាំ (១៩៨០ ដល់ ១៩៨៧ )**

| អត្ថបទ | ១៩៨០ | ១៩៨១ | ១៩៨២ | ១៩៨៣ | ១៩៨៤ | ១៩៨៥ | ១៩៨៦ | ១៩៨៧ | សរុប |
|---|---|---|---|---|---|---|---|---|---|
| ចំរៀងសម័យ | X | ២៨ | ៦ | ៨ | ២ | ៣ | ១ | X | ៤៨ |
| ល្ខោននិយាយ | X | ១ | ១ | ១ | X | X | X | X | ០៣ |
| ល្ខោនបាសាក់ | X | X | ១ | ១ | ៣ | X | ១ | X | ០៦ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ប្រលោមលោក | X | X | X | ១ | X | ១ | ១ | X | ១៣ |
| អាយ៉ៃរឿង | X | ១ | ២ | X | X | X | ១ | X | ០៤ |
| យីកេរឿង | ៣ | ៣ | ១ | ៣ | ១ | ២ | ២ | ១ | ១៦ |
| អាយ៉ៃឆ្លងឆ្លើយ | ៩ | ១៧ | ៧ | ១០ | ២ | ១ | X | X | ៤៦ |
| ចំរៀងបុរាណ | ១ | ១៧ | ១៨ | ៦ | ៤ | ៣ | ១ | X | ៥០ |
| សរុបតាមឆ្នាំ | ១៣ | ៦៧ | ៣៦ | ៣០ | ១២ | ១០ | ០៧ | ០១ | ១៧៦ |

## ※ ឈ្មោះស្នាដៃ មុនឆ្នាំ ១៩៧៥

| ល.រ | ឈ្មោះរឿង | ប្រភេទ | កាលបរិច្ឆេទនិពន្ធ |
|---|---|---|---|
| ១ | រឿងអ្នកលេងជាយសមុទ្រ | ប្រលោមលោក | ១៩៧០ |
| ២ | រឿង គុហារថ្មឈើង | -- | ១៩៧១-១៩៧២ |
| ៣ | រឿង អ្នកតាត្បូងខ្មៅ | -- | ១៩៧២ |
| ៤ | រឿង ឃាតកអាវ៉ាសែ | -- | ១៩៧២ |
| ៥ | រឿង ម្រាមភ្លើង | -- | ១៩៧៣ |
| ៦ | រឿង ម្រេញគង្វាល | -- | ១៩៧៤ |
| ៧ | រឿងយមរាជប្រមឹក | -- | ១៩៧៤ |
| ៨ | រឿង ដាវផ្កា ៦ពណ៌ | -- | ១៩៧៥ |
| ៩ | រឿង អញ្ជមកវិញហើយ | -- | ១៩៧៥ |

## ※ស្នាដៃមួយចំនួនក្រោយ ឆ្នាំ១៩៧៩ (តាមលំដាប់ឆ្នាំ)

| ល.រ | ឈ្មោះរឿង | ប្រភេទ | កាលបរិច្ឆេទនិពន្ធ |
|---|---|---|---|
| ១ | ជ្រោងទង់ប្រយុទ្ធដើម្បីបំបាត់ភាពមិនចេះអក្សរ | អាយ៉ៃឆ្លងឆ្លើយ | ១២.០៧ .១៩៨០ |
| ២ | អបអរខួបទី៣៥បុណ្យឯករាជ្យសាធារណរដ្ឋវៀតណាម | -- | ២៣.០៨. ១៩៨០ |

| | | | |
|---|---|---|---|
| ៣ | ពង្រឹងស្មារតីចំពោះឧបាយកលខ្មាំង | អាយ៉ៃឆ្លងឆ្លើយ | ១២ ០៩ ១៩៨០ |
| ៤ | ប្រជាជនកម្ពុជាអបអរ និងបុណ្យភ្ជុំបិណ្ឌតាមប្រពៃណី | -- | ០៦.១០.១៩៨០ |
| ៥ | រឿងទំងន់ទោសរបស់បនក្សត់ ប៉ុល ពតក្នុងភ្លើងនរកអវិចី | យីកេរឿង | ០៧.១០.១៩៨០ |
| ៦ | រឿង ៧ មករា ថ្ងៃជោគជ័យនៃបដិវត្តន៍ សង្គមនិយមបរិសុទ្ធ | -- | ៣០.១០.១៩៨០ |
| ៧ | រឿងមាយើង(យកតាមលំនាំដើម) | យីកេរឿង | ១៩.១១.១៩៨០ |
| ៨ | រឿង ជីវិតថ្មីក្រោយថ្ងៃ៧មករា | -- | ០១.០១.១៩៨១ |
| ៩ | រឿង ម៉ាកចឹង (៣ខ្សែ) | -- | ០៩.៦ ១៩៨១ |
| ១០ | រឿងការផ្ទេរតំណែងរវាងស្វានិងមាន់ | អាយ៉ៃរឿង | ៣១.០៨ .១៩៨១ |
| ១១ | រឿង ៧មករាមហាជោគជ័យ | យីកេ | ១៥.១២ .១៩៨១ |
| ១២ | រឿងទំងន់ទោសបនក្សត់ក្នុងភ្លើងអវិចី | -- | ១៩៨២ |
| ១៣ | រឿង វិធីផ្ទេរតំណែងរវាង មាន់និងឆ្កែ | អាយ៉ៃរឿង | ៣០.០៣.១៩៨២ |
| ១៤ | រឿង ចិត្តប្រណី (២ខ្សែ) | ល្ខោននិយាយ | ០៧.០៤.១៩៨២ |
| ១៥ | រឿង មាតាសន្ដោសប្រោសប្រណី | អាយ៉ៃរឿង | ១៤.០៨.១៩៨២ |
| ១៦ | រឿង ព្រះឥន្ទ្រខ្វាក់ភ្នែក (២ខ្សែ) | ល្ខោនបាសាក់ | ៣០.១១.១៩៨២ |
| ១៧ | រឿង យុនឆាងយុនផែន (៣ខ្សែ) | យីកេ | ០៧.០៤.១៩៨៣ |
| ១៨ | រឿង ប្រាំឆ្នាំក្នុងជីវិតថ្មី (១ខ្សែ) | -- | ០៣.១២.១៩៨៣ |
| ១៩ | រឿងសម្លេងនៃក្ដីសង្ឃឹម (១ខ្សែ) | -- | ០៩.១២.១៩៨៣ |
| ២០ | រឿង តេជោយ៉ត (៣ខ្សែ) | ល្ខោនបាសាក់ | ២៨.១២.១៩៨៣ |
| ២១ | រឿង វិលរកទ្រនំ | ល្ខោននិយាយ | ២៩.១២.១៩៨៣ |
| ២២ | រឿង វិលរកទ្រនំ | ប្រលោមលោក | ១៩៨៤ |

| | | | |
|---|---|---|---|
| ២៣ | រឿង នាងបដាចារ (២ខ្សែ) | ល្ខោនបាសាក់ | ០៦.០៤.១៩៨៤ |
| ២៤ | រឿង ឈាមពលករ (២ខ្សែ) | យីកេ | ០៧.០៤.១៩៨៤ |
| ២៥ | រឿង ស្នងស្ងួរមនោកែវ (១ខ្សែ) | -- | ២៧.០៦.១៩៨៤ |
| ២៦ | រឿង អារុណរះនៅទិសបូព៌ | ល្ខោនបាសាក់ | ២៨.០៦.១៩៨៤ |
| ២៧ | រឿង គូព្រេងចម្លែក (៤ខ្សែ) | -- | ០៥.១២.១៩៨៤ |
| ២៨ | រឿង ជនឥស្សរៈ (១ខ្សែ) | យីកេ | ០១.០១.១៩៨៥ |
| ២៩ | រឿង បុរសបេះដូងមាស (២ខ្សែ) | -- | ១៩.០៤.១៩៨៥ |
| ៣០ | រឿង កុំភ្លេចរឿងចាស់ (១ខ្សែ) | -- | ១៩.០៥.១៩៨៥ |
| ៣១ | រឿង មេឃបាត់ដួងច័ន្ទ | ប្រលោមលោក | ១៥.០៩.១៩៨៥ |
| ៣២ | រឿង ជីវិតអាថិកំបាំង (មិនទាន់ចេញផ្សាយ) | -- | ១៩៨៦ |
| ៣៣ | រឿង ព្រលឹងបន្ទាយស្រី (៥ខ្សែ) | ល្ខោនបាសាក់ | ១២.០៤.១៩៨៦ |
| ៣៤ | រឿង កងទ័ពគំរូ | អាយ៉ៃរឿង | ២៧.០៥.១៩៨៦ |
| ៣៥ | រឿង ក្បួនជីវិត (៣ខ្សែ) | យីកេ | ២៨.០៣.១៩៨៧ |
| ៣៦ | ចំរៀងបុរាណ ៥០បទ | | |
| ៣៧ | ចំរៀងសម័យ ៤៨បទ | | |

សេចក្តីបញ្ជាក់ : ចំរៀងអាយ៉ៃ ឆ្លងឆ្លើយ មានច្រើនណាស់តែចាំឈ្មោះតែប៉ុនប៉ុណ្ណោះ ។

# សេចក្តីផ្តើម

រឿង **តេជោយ៉ត** ជារឿងល្ខោនបាសាក់ល្បីល្បាញមួយក្នុងចំ-ណោមរឿងល្ខោន រឿងអាយ៉ៃ និងរឿងយីកេ ដ៏ច្រើនរបស់អ្នកនិពន្ធ **ទី ឌីម្លូត** ។ រឿងនេះបានចាក់ផ្សាយតាមវិទ្យុជាតិ ច្រើនលើកច្រើនសារក្នុងកំឡុងដើមឆ្នាំ១៩៨៧ និងឆ្នាំបន្តបន្ទាប់ហើយក៏មានការគាំទ្រយ៉ាងច្រើនពីសំណាក់មហាជនខ្មែរនាសម័យនោះ ។

រឿងតេជោយ៉ត បានបង្កប់អត្ថន័យយ៉ាងជ្រាលជ្រៅ នូវតម្លៃមនុស្សខ្មែរ ដែលយកប្រយោជន៍ជាតិជាធំ ។ ពួកគេមានទឹកចិត្តស្មោះស្ម័គ្រចំពោះជាតិមាតុភូមិ ចំពោះមហាក្សត្រ ថ្នាក់ដឹកនាំ រហូតដល់គ្រូបាអាចារ្យ ដោយមិនគិតថាខ្លួនជាបុរស ឬស្ត្រីឡើយ ។ ក្រៅពីនេះអ្វីដែលគួរឱ្យសរសើរនោះ គឺការទទួលខុសត្រូវនូវទង្វើរបស់ខ្លួន ដោយហ៊ានប្រឈមមុខនឹងបរិកាសសង្គមតានតឹង ក្នុងរនាំងអំណាចផ្តាច់ការបក្សពួកនិយម ដោយហ៊ានបកអាក្រាតអំពើអាក្រក់របស់ពួកឈ្លើងសង្គមដែលរមែងតែងតែយកជើងរាទឹក បន្ថយការរីកចំរើនរបស់ប្រទេសជាតិ។ កាលណាមានសង្គមគឺមានបញ្ហា ។ បញ្ហាចោទត្រូវបានដោះស្រាយដោយសន្តិវិធីខ្លះ ដោយហិង្សាខ្លះអាស្រ័យទៅលើប្រភេទបញ្ហា ។ តួ-យ៉ាងកំចាត់ជនក្បត់ជាតិត្រូវប្រើគ្រប់មធ្យោបាយ ដើម្បីចាប់ខ្លួនមេ-ដឹកនាំឱ្យបាន ព្រោះពួកនេះ ជាជនទីមួយដែលបង្កអសន្តិសុខ ធ្វើឱ្យ

ប្រជារាស្ត្ររស់ក្នុងការភ័យខ្លាច ហើយជាឱកាសឱ្យសត្រូវចូលអេកឈ្លានពានផងដែរ ។ ម្យ៉ាងទៀតជនឱកាសនិយមបង្កអំពើពុករលួយ បង្កើតបក្សពួក គិតប្រយោជន៍ផ្ទាល់ខ្លួនហួសហេតុ ក៏ជាសត្រូវដែលបឺតជញ្ជក់ផលចំណេញពីប្រទេសជាតិ ជាហេតុនៃការផ្តល់ឱកាសឱ្យពួកជាតិដទៃងាយនឹងចាប់ចំណុចខ្សោយ និងកេងយកប្រយោជន៍បានយ៉ាងងាយដែរ ។

ដូចនេះរឿងតេជោយ៉ត ជាស្នាដៃមួយអាចនាំឱ្យយុវជនខ្មែរជ្រើសរើសយកបាននូវចំណុចជាច្រើនធ្វើជាគំរូ ដើម្បីកសាងខ្លួនឯងក៏ដូចសង្គមជាតិឱ្យរីកចំរើនយ៉ាងពិតប្រាកដ ។

# សង្ខេបរឿង

នៅដែនដីកំពង់ស្វាយមានបុរសម្នាក់ឈ្មោះ "**មាស**" មានងារជាឧកញ៉ាតេជោបរមរាជ ដែលគេហៅថា "**តេជោមាស**" ។ លោកមានភរិយាឈ្មោះ "**ស្រែន្យ**" មានងារជាជំទាវ និងមានសិស្សជំនិតម្នាក់ឈ្មោះ "**យ៉ត**" ដែលតែងតែទៅសមរភូមិប្រយុទ្ធជាមួយនឹងលោកគ្រប់ទីកន្លែង ។ ស្វាមីភរិយាទាំងពីរនេះ មានទឹកចិត្តស្រឡាញ់រាប់អាន "**យ៉ត**" ជាពន់ពេក ។ ស្តេចសម្រែបានតាំងខ្លួនឯងថា "ស្តេចសម្រែរាជាធិរាជ" បានតាំងទីកងទ័ពនៅកំពង់ពោធិ៍ (កំពង់ឆ្នាំង) ដោយបានរៀបចំបន្ទាយមួយឱ្យឈ្មោះថា "បន្ទាយនគរ" ។ ស្តេចសម្រែជាមេក្រុមបះបោរប្រឆាំងនឹងស្តេចព្រះជ័យចេស្តាដើម្បីដណ្តើមអំណាចគ្រប់គ្រងផែនដី ។ តេជោមាសនិងយ៉តបានព្យាយាមលើកទ័ពទៅបង្ក្រាបក្រុមបះបោរនេះ ខ្លាំងណាស់ដែរ តែត្រូវបរាជ័យ ។ ជំទាវស្រែន្យបានរៀបចំល្បិចបញ្ឆោតឱ្យស្តេចសម្រែធ្លាក់ក្នុងអន្លង់ស្នេហា ចំពោះរូបនាងហើយបង្អកស្រាហូតដល់ស្រវឹង ។ ស្តេចសម្រែនិងបក្សពួកត្រូវបានតេជោមាស យ៉ត និងកងទ័ពចាប់ទៅថ្វាយព្រះចៅជ័យចេស្តាកាត់ទោសតាមច្បាប់នគរ ។

ក្រោយពីបានទទួលជោគជ័យលើស្តេចសម្រែរួចមក **តេជោមាស** បានទទួលអនិច្ចកម្មទៅ ។ ព្រះរាជាក៏ប្រទានងារនោះឱ្យទៅ **តេជោយ៉ត** បំពេញនាទីដឹកនាំកងទ័ពជំនួស ។ **តេជោយ៉ត** បានទទួលរាជបញ្ញានិង

ជាវិអាជ្ញាសឹកទៅបង្រ្កាបពួកឈ្លើយសឹកបះបោរ នៅខេត្តពោធិ៍សាត់ ។ ឆ្លងតាមបទពិសោធរបស់ឧកញ៉ាចក្រី និងក្រឡាហោមទទួលបរាជ័យក្នុងការបង្ក្រាបឈ្លើយសឹកនៅទីនោះ **តេជោយ៉ត** បានរកឃើញថាការចាញ់សង្គ្រាមនេះ បណ្ដាលមកពីមានខ្មាំងនៅក្រោយខ្នង ។ **តេជោយ៉ត** បានបញ្ជាកេណ្ឌទ័ពនៅលង្វែក កំពង់ស្វាយក្នុងនោះ មានម៉ឺនថៃចុងរ៉ាក់ដែលជាប្អូនថ្លៃមហាក្សត្រផងដែរ ។ ដើម្បីរកខ្មាំងខាងក្រោយខ្នង **តេជោយ៉ត** បានបញ្ជាឱ្យកងទ័ពកំណែនទាំងអស់ អូសឫស្សីបញ្ច្រាសចុងដើម្បីកសាងបន្ទាយ បើនរណាប្រឆាំងត្រូវសម្លាប់ចោល ។ បក្សពួកម៉ឺនថៃចុងរ៉ាក់មិនបានធ្វើតាមបញ្ជានេះឡើយ ហើយថែមទាំងធ្វើតាមទំនើងចិត្តរបស់ខ្លួន ព្រោះសំអាងទៅលើបងស្រីដែលធ្លាប់ទទួលសំណូកនិងជាអ្នកម្នាងនៃព្រះមហាក្សត្រនឹងជួយឱ្យរួចពីកំណែននេះ ។ ទង្វើនោះត្រូវ **តេជោយ៉ត** រកឃើញថា ម៉ឺនថៃចុងរ៉ាក់នេះឯង ជាខ្មាំងពីក្រោយខ្នង ហើយក៏ចាប់យកទៅសម្លាប់ចោលទៅ ។ ក្រោយពីបានទទួលដំណឹងថាប្អូនប្រុសស្លាប់ អ្នកម្នាងទូ បានទូលថ្វាយព្រះរាជាឱ្យចាប់ **តេជោយ៉ត** ទៅកាត់ទោសប្រហារជីវិត ។ ព្រះរាជាបានធ្វើតាមការសុំរបស់អ្នកម្នាង តែ**តេជោយ៉ត** មិនបានមកតាមបញ្ជានោះឡើយ ដោយសំអាងថា ខ្លួនជាប់ដៃបង្ក្រាបសត្រូវបះបោរចាំរួចការនេះ ខ្លួននឹងមកទទួលទោសដោយខ្លួនឯង ។ ដោយការទទូចសុំរបស់អ្នកម្នាងខ្លាំងពេក ព្រះរាជាបានបង្គំឱ្យ **តេជោយ៉ត** មកជួបតទល់ជាមួយអ្នកម្នាងទូ ។ ពេល

កំពុងជជែកគ្នានោះ **តេជោយ៉ត** បានចោទប្រកាន់ថា អ្នកម្នាងនូជាខ្មាំងពីក្រោយខ្នង ព្រោះបានរំខានខ្លួនធ្វើសឹកបើកឱកាសឱ្យសត្រូវវាយលុក និងទទួលសំណូកដើម្បីការពារ បក្សពួកម៉ឺនចៃចុងរ៉ាក់ធ្វើឱ្យកងទ័ពបាក់ស្មារតី ហើយក៏គប់កូនដាវសម្លាប់អ្នកម្នាងនូនាពេលនោះទៅ ។ **តេជោយ៉ត** ប្រកាសជំរាបមន្ត្រីទាំងនោះ ថាចាំបង្ក្រាបសត្រូវរួចនឹងចូលមកទទួលទោសពីព្រះអង្គដោយខ្លួនឯង ។

ការបង្ក្រាបឈ្លើយសៀមបះបោរបានសម្រេចជោគជ័យ **តេជោយ៉ត** ឱ្យគេធ្វើឃ្នាងហើយដាក់ខ្លួនឯង ដើរចូលទៅទទួលទោសពីព្រះរាជា ពីបទដែលខ្លួនបានសម្លាប់អ្នកម្នាងនូ ។ ព្រះរាជាមិនឱ្យចូលជួបរួចបញ្ជាឱ្យមន្ត្រីដោះលែង និងឱ្យទៅត្រួតការឯខេត្តកំពង់ស្វាយ ។ **តេជោយ៉ត** បានគួចចិត្តប៉ងប្រាថ្នាយកជំទាវស្រែន្យមកធ្វើជាភរិយាតែមិនបានសម្រេចទេ ព្រោះជំទាវបានគិតថា **យ៉ត** ជាជនជាតិភាគតិចហើយជាសិស្សរបស់ប្តីនាងពីមុនផងដែរ ។ ដោយសង្កេតឃើញជំទាវរើសអើងស្នេហាប្រកាន់វណ្ណៈបែបនេះ**តេជោយ៉ត**បានប្រើល្បិចលួចយកកាំជណ្ដើរផ្ទះជំទាវស្រែន្យមកឱ្យជាងដាប់ឆ្លាក់ជារូបព្រះពុទ្ធបដិមានិងរូប**តេជោមាស** ហើយប្រកាសធ្វើបុណ្យយ៉ាងធំបញ្ជូនកុសលទៅគ្រូរបស់ខ្លួន ។ ជំទាវស្រែន្យ បានទៅចូលរួមពិធីនេះហើយថ្វាយបង្គំព្រះពុទ្ធបដិមា និងរូបសំណាក **តេជោមាស** នោះ តែត្រូវបាន **តេជោយ៉ត** ប្រាប់ការពិតថាថ្វាយបង្គំកាំជណ្ដើរផ្ទះរបស់ខ្លួនឯង ។ គ្រានោះជំទាវស្រែន្យយល់ន័យនៃទង្វើរបស់ **តេជោយ៉ត** ហើយក៏ព្រមព្រៀងរៀបការជាមួយ **តេជោយ៉ត** នាពេលនោះទៅ ។

# អំពីតួអង្គ និងមុខងារ

១- តេជោមាស : ជាស្វាមីជំទាវស្រែន្យ មានងារជាតេជោបរមរាជ ត្រួតខេត្តកំពង់ស្វាយ ។

២- តេជោយ៉ត : ជាសិស្សតេជោមាស មានងារជាតេជោត្រួតខេត្តកំពង់ស្វាយពេលដែលតេជោមាសស្លាប់ទៅ ។

៣- ជំទាវស្រែន្យ : ជាភរិយារបស់តេជោមាស ជាស្ត្រីដែលមានល្បិចឆ្នើមអាចចាប់ស្តេចសម្រែក្បត់ជាតិយកទៅកាត់ទោស

៤- ព្រះចៅជ័យចេស្តា : មហាក្សត្រខ្មែរគង់នៅក្រុងឧត្តុង្គមានជ័យ ។

៥- អ្នកម្នាងនូ : បងស្រីម៉ឺនចៃចុងរ៉ាក់ និងជាអ្នកម្នាងរបស់ព្រះចៅជ័យចេស្តា ។

៦- ស្តេចសម្រែ : មេបះបោរបម្រុងដណ្តើមរាជ្យពីព្រះចៅជ័យចេស្តា ។

៧- ឧកញ៉ាពិភា : មន្ត្រីជំនិតរបស់ស្តេចសម្រែ ។

៨- ឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់ : បម្រើការងារជាមួយតេជោមាស និងតេជោយ៉ត ។

៩- នាងម៉ៃ : បុត្រីឧកញ៉ាព្រះស្រីទ្វារប្រាសាទដប់និងជាអ្នកតាមស្រឡាញ់តេជោយ៉ត តែមិនបានសម្រេច ក្លាយទៅជាប្អូនធម៌របស់តេជោយ៉តទៅវិញ ។

១០- នាយឈិត ៖ ឈ្លើយសឹកសៀម និងជាមេបះបោរប្រឆាំងព្រះរាជាខ្មែរ ។

១១- ម៉ឺនចៃចុងរ៉ាក់ ៖ ប្អូនអ្នកម្នាងនូ ប្រឆាំងតែជោយ៉ត ហើយត្រូវតែជោយ៉តចាប់ទៅសម្លាប់ចោល និងមានតួអង្គរំលឹកជាច្រើនទៀត

# កាលអាកាសរឿង

**ក-កាល ៖** រឿងរ៉ាវទាំងអស់បានប្រព្រឹត្តទៅក្នុងរជ្ជកាលព្រះបាទជ័យចេស្ដា (គ.ស ១៥៧៥-១៥៨៣)[(១)] ។

**ខ-អាកាស៖** នៅរាជធានីឧត្តុង្គ ខេត្តកំពង់ស្វាយ (ស្ទឹងព្រៃប្រស់) ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង (កំពង់ហៅ លង្វែក ...)

# គម្ពីរក្បួនព្យូហ៍សឹកខាំង១២

១- ត្រូវស្គាល់ទីណាត់ សម្រាប់លើកទ័ពជួបជុំគ្នា ព្រមទាំងទីបង្កប់ទ័ព និងទីសម្ងែងទ័ព ។

២- ត្រូវស្គាល់ចិត្តពលទាហានឱ្យច្បាស់ តើពលទាហានទាំងនេះ គោរពកោតខ្លាច និងទុកចិត្តលើមេទ័ពហើយឬនៅ ?

៣- ត្រូវស្គាល់ឱ្យច្បាស់នូវសូរស័ព្ទក្បួនទ័ពសឹករបស់បច្ចាមិត្ត ដែលលើកចូលមក ។ មេទ័ពមិនត្រូវភ្ញាក់ផ្អើល នឹងសូរស័ព្ទសន្ធឹកសឹកនិងសូរសម្រែកសត្វ មនុស្ស ឬពតិមានពាក្យចចាមអារាមផ្សេងៗនោះឡើយ បើឮហើយត្រូវពិចារណាឱ្យយល់ច្បាស់ ។

(១) ប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជាទំព័រ ១៨ របស់លោក សូរ អឿ ។

៤- ត្រូវឱ្យស្គាល់ស្ថានភាពធាតុអាកាស រដូវខ្យល់នៃតំបន់ទីដែលត្រូវចេញទៅប្រយុទ្ធនោះ ។

៥- បើមុននឹងចូលច្បាំង ត្រូវស្គាល់ឱ្យច្បាស់នូវច្រកទិសទីសម្រាប់ចូលប្រយុទ្ធ និងដកថយ ។

៦- ត្រូវចេះប៉ាន់ស្មាននូវកម្លាំងស្បៀងអាហាររបស់សត្រូវ និងស្បៀងអាហាររបស់ខ្លួនយើង ។

៧- ត្រូវស្គាល់ឱ្យច្បាស់ប្រាកដនូវកម្លាំង គ្រឿងសាស្ត្រាវុធ របស់ខ្លួន និងរបស់សត្រូវ ។

៨- ត្រូវស្គាល់ទីជយភូមិដែលនឹងត្រូវតាំងទីបន្ទាយរាយល្បាត ។

៩- ត្រូវឱ្យស្ទាត់ស្ទាញ ប៉ិនប្រសប់ក្នុងការចាត់តាំង អ្នកយាមល្បាត គឺកុំទុកចិត្តគេឱ្យហួសពីគំនិតរបស់ខ្លួនយើង ។

១០- ត្រូវចេះប្រើសេនា ទាហាន បើប្រើឱ្យទៅធ្វើការ ឱ្យចេះថ្លឹងថ្លែងឱ្យសមល្មមកម្លាំងទាហានយើង និងកម្លាំងទាហានសត្រូវ ។

១១- ត្រូវកាន់អាជ្ញាសឹកឱ្យរឹងមាំដូចផែនសិលា កុំត្រចៀកស្រាលឆាប់ជឿគេឥតពិចារណា ។

១២- រីឯព្រះករុណាអម្ចាស់ជីវិតដែលត្រាស់ប្រើមេទ័ពឱ្យចេញទៅច្បាំងនោះ ត្រូវកាន់ពាក្យសត្យឱ្យមេទ័ពទុកចិត្តកុំព្រួយបារម្ភ ពីទ័ពក្រោយឱ្យសោះ ។

(ដកស្រង់ចេញពីរឿងតេជោមាស តេជោយ៉ត របស់លោក គង្គ ប៊ុនឈឿន ទំព័រ១១២-១១៣)

**សំគាល់ :**

រឿងតេជោយ៉តស្នាដៃនិពន្ធ របស់លោក **ឌី ឌីហ្វូត** និងរឿង តេជោមាស តេជោយ៉ត ស្នាដៃនិពន្ធរបស់លោក **គង្គ ប៊ុនឈឿន** មានខ្លឹមសារសំខាន់ពីរខុសគ្នា គឺ :

| **រឿងតេជោយ៉ត** | **រឿងតេជោមាស តេជោយ៉ត** |
| --- | --- |
| - តេជោមាស ស្លាប់ដោយសារគ្រាំក្នុងខ្លួនក្រោយពីត្រូវបាតដៃមហាទម្ងន់របស់ស្តេចសម្រែ នៅពេលប្រយុទ្ធគ្នានៅឯដែនកំពង់ហៅ ។ | - តេជោមាសសម្លាប់ដោយការដុតខ្លួនឯង ដោយការតូចចិត្តចាញ់សំដីប្រពន្ធទី ២ (នាងម៉ែ) ។ |
| - នាងម៉ែជាកូនស្រីរបស់ឧកញ៉ាព្រហ្មស្រីទ្វារប្រាសាទដប់ដែលបានស្រឡាញ់តេជោយ៉តតែម្នាក់ឯង ។ | - នាងម៉ែជាស្រីបំរើនៅផ្ទះ តេជោមាស ។ ក្រោយមកបានក្លាយជាប្រពន្ធទី២របស់តេជោមាស ។ |

# រឿង គេហៅយើង

## បទប្រោរព្ទ

- លើកហត្ថប្រណម្យ អី អឹង អឺយ បង្គំនឹកគុណ អី អឹង អឺយ (២ដង) បក្សប្រជាជនបដិវត្តកម្ពុជា (២ដង) អី អឹង អឺយ បដិវត្តកម្ពុជា ។

- ភ្លឺដូចសុរិយា អី អឹង អឺយ រះលើមេឃា អី អឹង អឺយ (២ដង) ត្រួសត្រាយមាគ៌ាភ្លឺស្វាងបរិសុទ្ធ (២ដង) អី អឹង អឺភ្លឺស្វាងបរិសុទ្ធ ។

- មើលប្រាង្គអង្គរអី អឹង អឺយ រុងរឿងបំផុត អី អឹង អឺយ (២ដង) រចនាវិសុទ្ធ ដំណែលដូនតា (២ដង) អី អឹង អឺយ ដំណែលដូនតា ។

- នឹកគុណវីរៈអី អឹង អឺយ បុរសខេមរាអី អឹង អឺយ (២ដង) អង់អាចហានក្លាការពារមាតុភូមិ (២ដង) អី អឹង អឺយការពារមាតុ-ភូមិ ។

# ភាគទី ១

**តេជោមាស** : ខ្ញុំឈ្មោះ "មាស" មានគោរម្យងារជាឧកញ៉ាតេជោបរមរាជ... (ច្រៀង) តាំងចិត្តប្ដេជ្ញា ការពារទឹកដី ដូចជាប្រស្រីក្នុងកែវនេត្រា (២ដង) ទោះត្រូវលះបង់ អាយុសង្ខារ ក៏ចិត្តស្នេហាជាតិមិនរសាយ ។ (និយាយ) ជិតដល់ពេលចេញដំណើរ ហើយតើ ! ឯណាយ៉ត ?

**យ៉ត** : បាទលោកគ្រូ !

**តេជោមាស** : កងទ័ពរបស់យើងបានរៀបចំរួចរាល់ហើយរឺនៅ?

**យ៉ត** : បាទ!ខ្ញុំបាទត្រៀមរួចអស់ហើយ គឺយើងយកតែទ័ពសេះប៉ុណ្ណោះ តាមការគ្រោងទុកណាលោកគ្រូ !

**តេជោមាស** : អឺ! ល្អហើយ (សូរសម្លេងសេះកញ្ជ្រៀវខ្សៀវខ្សា...)

**ជំទាវស្រែស្ញ** : បងគិតចេញដំណើរឥឡូវនេះរឺ ?

**តេជោមាស** : ហ្នឹងហើយអូន ! ដល់ពេលវេលាបងហើយណា !

**ជំទាវស្រែស្ញ** : នេះថ្នាំព្យាបាលរបួសដែលបងតែងដាក់តាមខ្លួនអូនបាន រៀបចំជូនបងសព្វគ្រប់អស់ហើយ ។

**តេជោមាស** : អឺ ល្អហើយ !

**ជំទាវស្រែស្ញ** : ហ៊ឺ !រាល់ពេលមានកលយុគក្នុងនគរបងតែងមានភារកិច្ច ចេញធ្វើសឹកសង្គ្រាមជានិច្ច ។

តេជោមាស ៖ ស្រែន្យអូន !

ជំទាវស្រែន្យ ៖ ចាស់បង !

តេជោមាស ៖ បានធ្វើពលិកម្មបំរើជាតិយ៉ាងនេះ គឺជាកិត្តិយសមួយដ៏ធំធេងណាស់អូន

ជំទាវស្រែន្យ ៖ ចាស់!សូមបងប្រយ័ត្នប្រយែងណាំ ព្រោះអូនលឺគេថា ស្តេចសម្រែនោះខ្លាំងពូកែណាស់ណាបង !

តេជោមាស ៖ មិនអីទេអូន ! មិនអីទេ !

ជំទាវស្រែន្យ ៖ (ច្រៀង) អូនសូមជូនពរជោគជ័យ អឺ អឹង អឹយ (២ដង) ដល់រូបអ្នកប្តី អឺ អឹង អឹយ (២ដង)គួគាប់វាសនា សូមបងបានឈ្នះ លើពួកបច្ចា អឺ អឹង អឹយ .... ។

តេជោមាស ៖ ស្រែន្យអូន ! នៅផ្ទះចូរថែរក្សាខ្លួនប្រាណអោយបាន សុខចុះណាកុំព្រួយបារម្ភដល់បងអី! ណាអូន

ជំទាវស្រែន្យ ៖ ចាស! បងជាមេទ័ពខ្លាំងពូកែធ្លាប់មានស្នាដៃក្នុងសង្គ្រាម ការពារប្រទេសជាតិធំៗ ប៉ុន្តែរាល់ពេលដែលបងចេញទៅធ្វើសឹក អូន តែងគិតដល់សុខទុក្ខរបស់បងជានិច្ចណាំ

តេជោមាស ៖ អឺ ! មែនហើយអូនកុំគិតច្រើនពេកណាំ អូនស្រែន្យ ស្លាប់ក្នុងបុព្វហេតុការពារប្រទេសជាតិមាតុភូមិ ជាមហាកិត្តិ-យសដ៏ធំមែនទេអូន !

ជំទាវស្រែន្យ ៖ ចាំ ឯណាយ៉ត ?

យ៉ត ៖ បាទ !

**ជំទាវស្រែន្ស** : បំរើក្រួឯងឱ្យជិតដល់មែនទែនណា៎

**យ័ត** : បាទ ! សូមលោកជំទាវកុំបារម្ភអោយសោះ

**តេជោមាស** : ប្រពន្ធសំឡាញ់ បងលាហើយណា៎ !

**ជំទាវស្រែន្ស** : សូមបង ! ប្រកបតែជោគជ័យ និងសេចក្តីសុខណា៎បង !

**តេជោមាស** : សូមនៅឱ្យបានសេចក្តីសុខណាអូន បងលាសិនហើយ !

**ជំទាវស្រែន្ស** : ចា៎ះ ! ចា៎ះ ! (ស្ទូរជើងសេះចេញដំណើរ)

# ឆាកទី ២

ស្ដេចសម្រែ ៖ តាំងនាមខ្លួនឯងថា ព្រះសម្រែរាជាធិរាជមិនយូរមិនឆាប់យើងនឹងបានគ្រប់គ្រងរាជ្យជាស្ដេច នៅអាណាចក្រកម្ពុជាទាំងមូលមិនខាន (ច្រៀង) ដើមឡើយជារាស្ត្រ ស្រុកក្រាំងសម្រែឥឡូវពូកែ ដោយចេះវិជ្ជា (២ដង) តាំងខ្លួនជាស្ដេចមានកងយោធាល្បីល្បាញខ្ទរខ្ទារ អឺយ...កៀវកេណ្ឌពលរដ្ឋ...។ (និយាយ) ឯណាទៅលោកឧកញ៉ា ពិភា ?

ឧកញ៉ាពិភា ៖ ករុណាថ្លៃវិសេស !

ស្ដេចសម្រែ ៖ យើងបញ្ជាឱ្យរៃអង្គាសស្បៀង និងកេណ្ឌពលសឹក តើបានលទ្ធផលយ៉ាងណាដែរ ?

ឧកញ៉ាពិភា ៖ ករុណាថ្លៃវិសេស ! ទូលបង្គំបានបំពេញព្រះរាជបំណងរបស់ ព្រះអង្គប្រកបដោយជោគជ័យយ៉ាងប្រសើរ ព្រោះទូលបង្គំបានចាត់ឱ្យ មនុស្សដើរឃោសនាបញ្ចុះបញ្ចូលប្រជារាស្ត្រ ថាព្រះសម្រែរាជាធិរាជចេះមន្តវិជ្ជា ហៅទឹកភ្លៀងក្រាបទូល !

ស្ដេចសម្រែ ៖ ប្រសើរណាស់ៗ លោកទាំងអស់គ្នា ! បន្ទាយដែលយើងកំពុងសាងនៅភូមិស្វាយអំពារក្នុងដែនមឿងកំពង់ហៅនេះ ពុំទាន់រួចរាល់ទេ ប៉ុន្តែយើងសូមឱ្យ ឈ្មោះ "បន្ទាយនគរ" ព្រោះទីនេះ ហើយជារាជវាំងរបស់យើង ។ ដូច្នេះសូមលោកផ្សព្វផ្សាយប្រាប់ប្រជារាស្ត្រឱ្យហៅតាមលីទេ !

**ពួកមន្ត្រី** ៖ ករុណាថ្លៃវិសេស ! (មន្ត្រីពោលព្រមគ្នា)

**ស្តេចសម្រែ** ៖ អ៊ំ ! លោកឧកញ៉ាពិភា ត្រូវខិតខំកេណ្ឌពលសឹកបន្ថែមទៀត កុំបន្ធូរដៃឱ្យសោះ ។ ព្រោះនៅរដូវខាងមុខនេះយើងត្រូវលើកទ័ពទៅឡោមព័ទ្ធវាំងរបស់ ព្រះចៅជ័យចេស្តានៅក្រុងឧត្តុង្គដើម្បីដណ្តើមយករាជ្យសម្បត្តិ ក្រុងកម្ពុជាឱ្យបានដាច់ខាត !

**ឧកញ៉ាពិភា** ៖ ករុណាថ្លៃវិសេស ! ក៏ប៉ុន្តែឥឡូវនេះ បើតាមសេចក្តីរាយការណ៍របស់មេកងសោមថា តេជោមាស និងយ៉តបានលើកទ័ពមកវាយបន្ទាយយើងហើយក្រាបទូល !

**ស្តេចសម្រែ** ៖ អឺ ! ទ័ពវាមានច្រើន រឺ តិច ?

**ឧកញ៉ាពិភា** ៖ ឃើញមានប្រហែលជា ២០០ នាក់ប៉ុណ្ណោះ ក្រាបទូល !

**ស្តេចសម្រែ** ៖ តែប៉ុណ្ណេះ តេជោមាសវាធ្លាក់ក្នុងអន្ទាក់យើងហើយ ។ ហ៊ឹះ ! ពីថ្ងៃមុនវាចាត់ភ្នាក់ងារសំងាត់ឱ្យនាំសំបុត្រទៅប្រាប់ចៅម៉ឿងគោកសេះ និងចៅម៉ឿងកំពង់ហៅ ។ ប៉ុន្តែត្រូវទ័ពយើងចាប់បាននាំមកឱ្យយើង យើងសំលាប់បាត់ទៅហើយ ។ តេជោមាស និងយ៉តវាមិនដឹងថា ផែនការរបស់វានេះ ត្រូវយើងបំផ្លាញទេ ទើបវាហ៊ាននាំទ័ពតែ ២០០ នាក់ មករកស្លាប់អត់មានគិតមុខក្រោយយ៉ាងនេះ ។ ហាំ ! ហាំ ! បើសម្លាប់តេជោមាសបាន ព្រះចៅចេស្តាដូចជាបាក់ដៃមួយចំហៀងអញ្ចឹង ។ ឥឡូវនេះអស់លោកប្រុងប្រៀបទទួលសង្គ្រាមជាមួយពួកវាទៅ !

# ភាគទី ៣

**យ៉ត** : យី ! លោកគ្រូ ! ហេតុអ្វីបានជាមិនឃើញទ័ពចៅមឿង ទាំងពីរអញ្ចឹង ?

**តេជោមាស** : មែនហើយ ! យ៉ត ! វីរផែនការរបស់យើងប្រហែលរលាយខូចអស់ហើយទេដឹងមើលទៅ ! យ៉ត ! (និយាយមិនទាន់ផុតកន្ទុយពាក្យផងស្ដេចសម្រែក៏ចូលមកដល់)

**ស្ដេចសម្រែ** : អូ ! តេជោមាសឯងមកដល់ហើយរឺ ?

**តេជោមាស** : ហ៊ឺ ! ស្ដេចសម្រែស្គាល់យើងច្បាស់ណាស់ហ្ន៎ !

**ស្ដេចសម្រែ** : យើងដឹងថា តេជោមាស និងសិស្សជំនិតឈ្មោះយ៉តនោះ មានថ្វីដៃខ្លាំងពូកែណាស់ រហូតវាយឈ្នះទ័ពព្រះចៅថៃណាក្រុងទេពបុរីស្រីព្ធយុធ្យាផង !

**តេជោមាស** : នែ ! ស្ដេចសម្រែបើអ្នកដឹងខ្លួនដូចនេះ ចូរឯងចូលខ្លួនអោយយើងនាំចូលទៅក្រុងឧត្ដុង្គតាមសម្រួលភ្លាមទៅ !

**ស្ដេចសម្រែ** : តែផ្ដាស ! (ពោលទាំងគំហក) ថ្ងៃនេះយើងនឹងឱ្យគ្រូសិស្សរបស់ឯងស្គាល់ស្នាដៃស្ដេចសម្រែយើងម្ដងហើយ !

(ច្រៀង) នែ៎ តេជោមាស ពាសពាលល្ងង់ខ្លៅ នឹងចូលរណ្ដៅ ៗ ក្នុងថ្ងៃហ្នឹងហើយ (២ដង) កុំបាច់អួតអាង១ យើងមិនខ្លាចឡើយ ឯងចូលបង្អើយ១ មករកមរណា ......

តេជោមាស (ច្រៀងបន្ត) នែ៎ ! ស្តេចសម្រែ ឯងពូកែពិតតែ ចិត្តគំនិតលោភលន់ផ្តាច់ការ (២ដង) ធ្វើបាបឱ្យរាស្ត្រ រងទុក្ខខ្លោចផ្សា យើងស្តាប់អាជ្ញា ចូលមកចាប់ខ្លួន......។

ស្តេចសម្រែ : ហ៊ឺ ! កុំដេកយល់សប្តិអោយសោះ បើឯងអាច ចាប់ព្រះអាទិត្យបានទើបឯងអាចចាប់ព្រះសម្រែរាជាធិរាជយើងនេះបាន

យ៉ត : ស្តេចសម្រែអ្នកឯងស្មានថាមេឃប៉ុនគ្របឆ្នាំងដូចកង្កែប ក្នុងបាតអណ្តូងហើយ ។ ភ្នំមួយខ្ពស់នៅមានភ្នំមួយខ្ពស់ជាងទៀតណា !

ស្តេចសម្រែ : យ៉ាងម៉េចយ៉ត ! ឯងស្គាល់ប្រវត្តិដើមយើងទេ មុនពេល ដែលយើងប្រកាសតាំងខ្លួនជាស្តេចនេះ !

យ៉ត : យើងស្គាល់ច្បាស់ណាស់ ដើមឡើយឯងជារាស្ត្រម្នាក់ ឈ្មោះ សំ នៅក្រាំងសម្រែខេត្តបរិបូណ៌នេះ

ស្តេចសម្រែ : ចាំល្អណាស់

យ៉ត : ហើយបានទៅសិក្សាគុណវិជ្ជានៅ ភ្នំទូកមាស ខេត្តកំពង់ស្វាយ លុះដល់ចេះវិជ្ជាខ្លាំងពូកែហើយ អ្នកឯងមិនយកសមត្ថភាពរបស់ខ្លួន ទៅបំរើប្រទេសជាតិបែរជាបង្កចលាចលបំបះបំបោរបង្កើតទ័ពទឹង ហើយប្រកាសឈ្មោះខ្លួនឯងថា ព្រះសម្រែរាជាធិរាជ បណ្តាលឱ្យមាន អសន្តិសុខក្នុងនគរ នាំប្រជារាស្ត្រ ឱ្យធ្លាក់ទៅក្នុងគ្រោះមហន្តរាយ

ស្តេចសម្រែ : ហើយវាយ៉ាងម៉េច !

យ៉ត : វាបណ្តាលមកពីសង្គ្រាមលោភលន់របស់ឯង !

ស្តេចសម្រែ : យ៉ត ! យ៉ត ! ស្គាល់ប្រវត្តិយើងច្បាស់ណាស់

ដូច្នេះឯង គួរស្គាល់កិរិតថ្វីដៃរបស់យើងដែរ ។ នែ៎ ! បើចង់សុខខ្លួន តោងចុះចូលធ្វើការបំរើសម្រែយើងនេះមក ។

**តេជោមាស** : ហ៊ឺះ!អាមនុស្សថោកទាប ការស្រមើស្រមៃដ៏ស្អុយគគ្រុករបស់ឯងនេះ ! វានឹងនាំឱ្យខ្លួនឯងវិនាសអន្តរាយជាមិនខានទេ !

**ស្តេចសម្រែ** : ល្អ ! គ្រូ និងសិស្សឯងទាំងពីរនាក់ ត្រូវចោលឆ្អឹងនៅមាត់ទ្វារបន្ទាយនគរក្នុងថ្ងៃនេះហើយ (រួចស្រែកបញ្ជា) កងទ័ពទាំងអស់គ្នាចូលសំលាប់ពួកវាកុំឱ្យរត់រួចម្នាក់អោយសោះ ! (កងទ័ពទាំងសងខាងកាប់ចាក់គ្នាយ៉ាងសាហាវ ។ ទីបំផុតទ័ពស្តេចសម្រែបានទទួលជោគជ័យ)

**យ៉ត** : លោកគ្រូ !

**តេជោមាស** : យ៉ាងម៉េចយ៉ត !

**យ៉ត** : ទ័ពយើងស្លាប់ របួស និងរត់ខ្ចាត់ខ្ចាយអស់ទៅហើយ ដូច្នេះយើងត្រូវដកថយទើបបានព្រោះទ័ពយើងៗ ស្លាប់ច្រើនណាស់ !

**តេជោមាស** : មែនហើយយ៉តត្រូវហើយ យើងគេចដោះខ្លួនទៅខាងណោះវិញ... តោះយើងទៅភ្លាម (អ្នកទាំងពីររត់គេចរហូតដល់ច្រកភ្នំ )

**យ៉ត** : ហ៊ឺ ! រត់មកដល់ច្រកភ្នំនេះ បែកគ្នាអស់ទៅហើយលោកគ្រូនៅសល់តែយើងពីរនាក់ទេ !

**តេជោមាស** : ហ៊ឺ ! គ្រូឈឺចិត្តណាស់យ៉ត មិនគួរចាញ់ដៃអា-

មនុស្សក្បត់ជាតិហ្នឹងសោះ ! (ច្រៀង) ច្រកអើយច្រកភ្នំ ក្តៅងំក្នុងចិត្ត អើ.....ចាញ់ជនឧក្រិដ្ឋត្បិតខូចផែនការ ធ្លាប់មានថ្វីដៃ នឹងស្តេច ថៃណា ការពាររដ្ឋាយកជ័យគ្រប់ទិស.....។

**យ៉ត** : លោកគ្រូ យើងបរាជ័យ ព្រោះយើងមានទ័ពតិចជាងសត្រូវទេ ខ្ញុំឆ្ងល់ណាស់ ហេតុអ្វីចៅម៉ឿងគោកសេះ និងចៅម៉ឿងកំពង់ហៅ មិនលើកទ័ពមកតាមបញ្ជាលោកគ្រូសោះ ឬមួយសំបុត្រសម្ងាត់នោះ មិនបានទៅដល់ដៃពួកគាត់ទេ ?

**តេជោមាស** : យ៉ត ! ប្រហែលជាអញ្ចឹងហើយមើលទៅបានជាបាត់ ឈឹងអញ្ចឹង ! (គ្រានោះស្តេចសម្រែក៏មកដល់)

**ស្តេចសម្រែ** : ហាំ ! ហាំ ! តេជោមាស ឯងរត់ដល់ក្រហែងមេឃណា ក៏នៅយើងតាមទាន់ដែរ !

**យ៉ត** : យី ! ស្តេចសម្រែ ! លើកគ្នាមកច្រើនណាស់ (យ៉ត ពោលដោយតក់ស្លុត)

**តេជោមាស** : ឯងប្រយ័ត្នខ្លួនបន្តិចណាំ

**ស្តេចសម្រែ** : តេជោមាស ! ឯងធ្លាប់មានឈ្មោះល្បីពូកែធ្វើសឹកសង្គ្រាមណាស់ចុះហេតុអីក៏រត់យកព្រះអាយុអញ្ចឹង ?

**តេជោមាស** : ហ៊ឺស ! មនុស្សក្បត់ជាតិ ឯងមិនបាច់មកប្រើពាក្យចាក់ចុចទៀតទេ ពេលនេះយើងប្តូរជីវិតជាមួយឯងហើយអាសម្រែ !

**ស្តេចសម្រែ** : ហាក ! ចូលមកសាកស្នៀតដាវរបស់យើងមើល ! (គូបដិបក្ខប្រកាប់ប្រចាក់គ្នាយ៉ាងសាហាវ ហើយស្តេចសម្រែលើកដាវបំរុងចាក់សម្លាប់តេជោមាស តែយ៉តលោតទៅកាប់រង...)

យ៉ត : នែ៎ ! ឯងសាកក្បាច់គុនផ្តាក់របស់យើងសិនទាល់តែកន្លងខ្មោចយើងរួចទើបឯងអាចសម្លាប់គ្រូយើងបាន ។

ស្តេចសម្រែ : យី ! អាចង្រៃនេះវាសំបើមណាស់តើ វាកាប់បាក់ថែងដាវរបស់ឯងរំដោះតេជោមាសទៅបាត់ ។ ពួកយើងដេញតាមភ្លាម ។

........................................................................................

យ៉ត : លោកគ្រូ វាដាល់ត្រូវមួយដៃអំបាញ់មិញ យ៉ាងម៉េចទៅហើយលោកគ្រូ ?

តេជោមាស : មិនអីទេ ! កុំគិត ស្រួតទៅទៀតចុះ ក្រែងវាដេញទាន់ណា !

យ៉ត : យី ! ទ័ពសេះពួកណាគគ្រឹកគគ្រេងពីមុខនោះ ។ អ៊ូ ! លោកគ្រូ អ្នកជិះសេះសខាងមុខ គឺមឿងកំពង់ហៅទេ !

តេជោមាស : អូ ! ច្បាស់ហើយយ៉ត ប្រសើរណាស់ៗ ម្នាក់ស្គាយធ្ងូ ក្បែរនោះមិនគឺមឿនគោកសេះទេឬ? តោះទៅស្កាត់មុខភ្លាមទៅណា !

# ភាគទី៤

ជំទាវស្រែន្យ : បង ! ហេតុអីតាំងពីមកពីធ្វើសឹកជាមួយស្ដេចសម្រែវិញ បងចេះតែអង្គុយសញ្ចប់សញ្ជឹងមិននិយាយស្ដីដូចនេះ បងកើតទុក្ខកង្វល់អីហ្នឹង

តេជោមាស : ស្រែន្យ ! អូន

ជំទាវស្រែន្យ : ចាស !

តេជោមាស : វាជាកិច្ចការប្រទេសជាតិ អូនកុំចង់ដឹងធ្វើអីនាំតែអំពល់ក្នុងចិត្តទេណាអូន !

ជំទាវស្រែន្យ : យី ! ប្ដីសម្លាញ់អើយ ហេតុអីបងពោលដូច្នេះ គូស្វាមីភរិយា តែងចេះដឹងទុក្ខធុរៈគ្នាទៅវិញទៅមក ។ លើសពីនេះទៀត ស្ត្រីក៏អាចបំរើប្រទេសជាតិបានដែរណា ! ហេតុអ្វីបានជាមិនចង់ឱ្យអូនដឹងអញ្ចឹង ? (ច្រៀង) ឱស ! ឱស្វាមីសម្លាញ់ចិត្តអូន ហេតុអ្វីស្រពោនមិនស្ដីចរចា បងមានកង្វល់អំពល់ម្ដេចម្ដា ក៏ម្ចាស់ចិន្ដាថ្លែងប្រាប់ភរិយា .........។

តេជោមាស : (ច្រៀងបន្ត) បងសែនអាណិត ស្និទ្ធស្នេហ៍ពេកក្រៃ មិនចង់ឱ្យថ្លៃ កើតទុក្ខគ្រាំគ្រា បងធ្វើចុតហ្មាយ ថ្វាយព្រះរាជាពួកជនក្បត់ជាតិ ខ្លាំងពូកែណាស់....។

ជំទាវស្រែន្យ : អុំ ! បងពិបាកចិត្តពីរឿងស្ដេចសម្រែនោះឬ ?

មូលនិធិខ្មែរសម្រាប់ការសិក្សា    ករុណាខ្មែរ

កញ្ញា ជាង សុភ័ត្រា